# ដើរតាមផ្លូវនេះ

Puyallup Watershed Initiative
Active Transportation
www.pwi.org/activetransportation

## ទាំងនេះ គឺជាគន្លឹះមួយចំនួនដើម្បីជួយអ្នកឲ្យមានដំណើរកម្សាន្តដ៏អស្ចារ្យ៖

**យើងទាំងអស់គ្នាគឺជាអ្នកថ្មើរជើង។** មិនថាអ្នកកំពុងរុញរទេះដឹកកូនង៉ែត ប្រើប្រាស់ឧបករណ៍ចល័ត ឬកំពុងដើរពីកន្លែងចំណតទៅច្រកចូលហាងទំនិញនោះទេ ការដើរគឺជាវិធីដ៏សប្បាយរីករាយមួយក្នុងការដើរមើលកន្លែងផ្សេងៗដើម្បីស្វែងយល់ពីសង្កាត់របស់អ្នក។

**ត្រូវមានប្រុងប្រយ័ត្នទុកជាមុន។** មនុស្សគ្រប់រូប ត្រូវអនុវត្តតាមវិធានចរាចរណ៍ផ្លូវគោក និងគោរពភ្លើងសញ្ញានិងស្លាកសញ្ញាចរាចរណ៍ តាមតែពួកគេសម្រេចចិត្តធ្វើដំណើរ។ ទាំងអស់នេះ គឺជាស្លាកសញ្ញានិងភ្លើងសញ្ញាសំខាន់ៗដែលត្រូវយល់ដឹង៖




ស្លាកសញ្ញាឈប់




ស្លាកសញ្ញាសិទ្ធិអាទិភាព



ប្រុងប្រយ័ត្នថ្មើរជើងឆ្លងកាត់



តំបន់សាលារៀន



**សញ្ញាអនុញ្ញាតឲ្យដើរឆ្លងកាត់៖** ចាប់ផ្តើមដើរឆ្លងកាត់ផ្លូវ ដោយពិនិត្យក្រែងមានយានយន្តកំពុងធ្វើដំណើរ។



**សញ្ញាហាមដើរឆ្លងកាត់៖** នៅពេលលោតភ្លើងសញ្ញានេះ ត្រូវដើរឆ្លងកាត់ឲ្យបានលឿន បើកំពុងស្ថិតនៅលើផ្លូវប្រសព្វ ឬហាមដើរឆ្លងកាត់។ ប្រសិនបើសញ្ញានៅសៀមមិនទាន់លោត ហាមដើរចូលក្នុងផ្លូវប្រសព្វ។

**ចិញ្ចើមផ្លូវនិងផ្លូវដើរ គឺជាកន្លែងល្អបំផុតស្រមាប់ដើរ។** ប្រសិនបើគ្មានចិញ្ចើមផ្លូវឬផ្លូវដើរទេនោះ ត្រូវដើរបែមុខទៅរកចរាចរណ៍ដើម្បីមើលនិងកំណត់រថយន្តដែលចូលមកជិតអ្នកបានងាយស្រួល។

**ដើរឆ្លងកាត់ផ្លូវនៅត្រង់ផ្លូវប្រសព្វដែលមានភ្លើងសញ្ញាចរាចរណ៍ ឬមានគំនូសសញ្ញាស្រមាប់ថ្មើរជើងឆ្លងកាត់នៅពេលណាដែលអាចដើរឆ្លងកាត់បាន** ប្រសិនបើពុំមានភ្លើងសញ្ញាឬគំនូសសញ្ញាស្រមាប់ថ្មើរជើងឆ្លងកាត់ទេនោះ ការដើរឆ្លងកាត់ផ្លូវនៅត្រង់ចំណុចប្រសព្វរវាងផ្លូវពីរ គឺជាជម្រើសដ៏ល្អបំផុតបន្ទាប់។ តាមច្បាប់រដ្ឋ គ្រប់ផ្លូវប្រសព្វទាំងអស់គឺជាកន្លែងស្រមាប់អ្នកថ្មើរជើងឆ្លងកាត់ (មិនថាមានឬគ្មានគំនូសសញ្ញានោះទេ) ប៉ុន្តែមិនមែនអ្នកដែលកំពុងបើកបរ ឬជិះកង់ទាំងអស់សុទ្ធតែផ្តល់អាទិភាពទៅផ្លូវខាងស្តាំដែរនោះទេ។ ត្រូវមានភាពឆ្លាតវៃ និងមានការប្រុងប្រយ័ត្ន!

**ត្រូវមើលផ្លូវទាំងសងខាងមុនពេលបោះជំហានចូលក្នុងផ្លូវថ្នល់។** លើកដៃធ្វើសញ្ញាថាអ្នកចង់ឆ្លងកាត់ផ្លូវ ហើយប្រសិនបើអាចធ្វើបាន ត្រូវសម្លឹងមើលអ្នកដែលកំពុងបើកបរឬអ្នកដែលកំពុងជិះកង់។ ត្រូវមានយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកដែលអាចបត់ឆ្វេងឬបត់ស្តាំ។ ពួកគេអាចមិនបានពិនិត្យមើលនរណាម្នាក់ដែលកំពុងដើរឆ្លងផ្លូវ។

**ត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច និងត្រូវក្រឡេកមើលជុំវិញខ្លួន។** នៅពេលកំពុងធ្វើដំណើរតាមល្បឿននៃការដើរ វាកាន់តែមានភាពងាយស្រួលក្នុងការពិនិត្យមើលសង្កាត់របស់អ្នកឲ្យបានល្អិតល្អន់ និងនៅក្នុងការកត់សម្គាល់ពីការផ្លាស់ប្តូរនានានៅក្នុងពិភពធម្មជាតិនេះ។ រីករាយនឹងការដើរកម្សាន្តរបស់អ្នក!

**ស្លៀកសម្លៀកបំពាក់ត្រឹមត្រូវស្រមាប់អ្នកថ្មើរជើង។** ពិចារណាស្លៀកសម្លៀកបំពាក់ដែលមានពណ៌ភ្លឺ និង/ឬចាំងពន្លឺ ដើម្បីធ្វើឲ្យងាយខ្លួនអ្នកអាចមើលឃើញច្បាស់ជាពិសេសនៅក្នុងពេលយប់ ពេលព្រលឹម ឬព្រលប់ និងក្នុងអំឡុងពេលនៃឆ្នាំដែលមានអាកាសធាតុស្រអាប់ ។ ការយកពិលតាមខ្លួន អាចជួយធ្វើឲ្យខ្លួនអ្នកមើលឃើញច្បាស់ និងអាចកំណត់ពីគ្រោះថ្នាក់ដែលអាចកើតមានតាមចិញ្ចើមផ្លូវ ឬលើដងផ្លូវ។

**ត្រូវមានការប្រុងប្រយ័ត្នចំពោះអាកាសធាតុ។** ប្រសិនបើមានអាកាសធាតុត្រជាក់ និងមានភ្លៀងធ្លាក់ ត្រូវពាក់សម្លៀកបំពាក់កក់ក្តៅ ឬសម្លៀកបំពាក់មិនជ្រាបទឹក ឬត្រូវប្រើឆ័ត្រ។ ប្រសិនបើអាកាសធាតុក្តៅ និងមានពន្លឺថ្ងៃ ត្រូវយកដបទឹកតាមខ្លួន និងត្រូវការពារស្បែករបស់អ្នកដោយពាក់មួក អាវក្រៅដែលមានពណ៌ស្រាល និង/ឬឡេការពារកម្តៅថ្ងៃ។

**ត្រូវមានការប្រុងប្រយ័ត្នជាពិសេសនៅពេលកំពុងដើរឆ្លងកាត់ផ្លូវចង្អៀតនិងផ្លូវបើកបរ។** សូមចងចាំថាត្រូវសម្លឹងមើលចរាចរណ៍យានយន្តនិងទាច្រកយាននៅត្រង់ផ្លូវប្រសព្វ ប្រៀបដូចជាអ្នកត្រូវមើលចរាចរណ៍យ៉ាងពិសេសត្រង់ចំណុចប្រសព្វរវាងផ្លូវពីរដែរ។

**ក្តារស្គី និងស្គូទ័រ វិធីដែលផ្តល់ភាពសប្បាយរីករាយ និងមានប្រសិទ្ធភាពក្នុងការធ្វើដំណើរ!**
ការពារក្បាលរបស់អ្នកដោយពាក់មួកសុវត្ថិភាពគ្រប់ពេលវេលាទាំងអស់ដែលអ្នកបើកបរ។ អ្នកប្រើឧបករណ៍ដែលមានកង់ ត្រូវផ្តល់អាទិភាពចំពោះចរាចរណ៍ដែលយឺតជាង និងត្រូវមានការប្រុងប្រយ័ត្ននិងគិតគូរដល់មនុស្សដទៃផ្សេងទៀត។ នៅពេលជិះស្គូទ័រ ឬក្តារស្គី អ្នកត្រូវមានការប្រុងប្រយ័ត្នបន្ថែមទៀតនៅពេលឆ្លងកាត់ផ្លូវបើកបរ ឬចូលដល់ផ្លូវប្រសព្វ ដោយសារអ្នកបើកបររថយន្តអាចមិនបានចាប់ភ្លឹកដល់អ្នកប្រើប្រាស់ចិញ្ចើមផ្លូវដែលកំពុងធ្វើដំណើរក្នុងល្បឿននៃល្បឿននោះទេ។

**តើមានអ្វីកំពុងរាំងផ្លូវរបស់អ្នកដែរឬទេ ដូចជាដើមឈើបែកបីដែលដុះគ្របពាសពេញ ឬស្មៅមេប្រះធំនៅលើចិញ្ចើមផ្លូវជាដើម?**
ត្រូវឲ្យគេបានដឹង ដោយរាយការណ៍បញ្ហានេះទៅកាន់អាជ្ញាធរក្រុងឬខោនធីដែលសម្រសប។

នៅក្នុងដែនអធិបតីរបស់ទីក្រុង Tacoma សូមហៅទៅលេខ 311 ឬ (253) 591-5000 ដើម្បីទាក់ទងទៅបុគ្គលិកដើម្បីប្រគល់ជូននូវព័ត៌មានលម្អិតនៃបញ្ហានោះ។ កម្មវិធីទូរស័ព្ទ TacomaFIRST 311 គឺជាជម្រើសមួយផ្សេងទៀតដើម្បីធ្វើការស្នើសុំនិងតាមដានសេវាកម្ម។

